ឧប សៅ សង្ហា

# មនោសាស្ត្រ នៃ ការតស៊ូជាត

ESPRIT DE LA RESISTANCE NATIONALE



សារលភាព (simplicité)

## មាតិការឿង


ទស្សន: នៃ ការតស៊ូ ........................................ 2

តើ ការតស៊ូជាតិ  ជា សត្រូវនឹង សន្តិភាព នោះឬ ? ........................ 7

សេចក្តីសន្និដ្ឋាន ........................................ 9

# មនោសាស្ត្រ នៃ ការតស៊ូជាតិ

## ទស្សនៈ នៃ ការតស៊ូ

ការតស៊ូ ប្រឆាំង នឹង អយុត្តិធម៌, អំណាចផ្តាច់ការ, អាណានិគមនិយម, ការកាន់កាប់បរទេស មាន គោលវិធី ពីរយ៉ាង៖ ហិង្សា និង អហិង្សា។ ជម្រើស យក វិធី ណាមួយ មក អនុវត្ត វា អាស្រ័យ ទៅលើ បរិបទនៃបញ្ហា។ ជម្រើស វិធី ដោយតាន់ច្រឡំ វានាំបង្កើត ទ្វេផលវិបាក៖ ការរើរឹតតែខ្លាំងឡើង នៃ បញ្ហា និង ការបាត់បង់ នៃ វិញ្ញាណ នៃ ការតស៊ូ។ អាស្រ័យហេតុនេះ អ្នកដឹកនាំ នៃ ការតស៊ូវ ត្រូវ ធ្វើ រោគវិនិច្ឆ័យនៃបញ្ហា អោយបាន ត្រឹមត្រូវ មុននឹង យក វិធី ណាមួយ មក អនុវត្ត។

គេដឹងថា អាទិ នៃ មនោសាស្ត្រ នៃ ការតស៊ូ គឺ កលហាពិរោធ[1] ប្រឆាំងនឹង អំពើ អយុត្តិធម៌ ដែលគំរាមដល់សេរីភាព។ កលហាពិរោធ គឺ ជា ការកម្រើកនៅ មួយកន្លែង,ការងើបឡើង នៃ អ្នករងគ្រោះ ឮលាន់រំពងហើយ រក្សា មិនអោយ សាបសូន្យទៅបាន។ ជា ប្រពលតាព[2] ដែល គ្មាន គោលបំណង ដណ្តើម អំណាចគ្មានទីបញ្ចប់ ហើយគ្មាន តណ្ហា ជាគោលដៅ។ អាស្រ័យហេតុនេះ កលហាពិរោធ មិនមែនជាកម្លាំង យោធាឬ យុទ្ធក: ; វា មិនមែន ជា កងទ័ព មានការរៀបចំ ប្រដាប់អាវុធដើម្បី យកកម្លាំងមកប្រើ ជា អំណាច។ ប៉ុន្តែ កម្លាំងនេះ មិនចេះស្ងៀយ និង មិនរំសាយ នៅតែបន្តប្រឆាំង ទាមទារ យ៉ាងសកម្ម។ ការចចេស, មាន:, សេចក្តីក្លាហាន នៃ អ្នករងគ្រោះ នាំគ្នាឈរ ទន្ត្រំជើង ឬ អង្គុយ នៅមួយកន្លែង ស្រែកហើយ ស្រែកទៀត បញ្ចេញកំហឹងនិង ការឈឺចិត្ត មិន ចេះ ចប់ ដែល នាំបង្កើត ជា កម្លាំង ការតស៊ូ មិនអាចទប់ទល់ និងមិនអោយសាបសូន្យ ទៅបាន។

[1] កលហាពិរោធ = កំហឹង ; emportement។
[2] ប្រពលភាព = intensité de forces។

នៅក្នុង ករណី អំណាចផ្តាច់ការ ដែល ប្រព្រឹត្តិ អំពើ ព្រៃផ្សៃ គ្រប់បែបយ៉ាង ដល់ ប្រជាជន គឺ ជា ដែកកេះឡើង ដុត អោយឆេះ ប្រជាកំហឹង នាំអោយ អ្នករងគ្រោះ មាន កលហាពិរោធ ជា កម្លាំង ធម្មានរូប នៃ ការតស៊ូជាតិ មាន គោលដៅ ច្បាស់លាស់ គឺ ការប្រឆាំង តប ដើម្បី ទាមទារ សិទ្ធិសេរីភាព ជា ពលរដ្ឋ។ កម្លាំង តស៊ូជាតិ បែបនេះអាចកើតមាន បាន លុះត្រា តែមាន អ្នកដឹកនាំ មាន ទេពកោសល្យ ចេះ ច្នៃ នូវកលហាពិរោធ នៃ ប្រជាជន អោយ ក្លាយជា កម្លាំងរៀបចំ មាន អង្គការ តស៊ូ មាន គោលការណ៍ មាន គោលដៅ មាន ក្រុម អ្នកដឹកនាំ មាន មេដឹកនាំ ដែល ជា មគ្គុទេសបង្ហាញ នូវ វិធី ដែល ត្រូវយក មក អនុវត្ត ៤ បាន ថ្លឹងថ្លែងនឹង ហេតុបញ្ហា។ ចំពោះ មេដឹកនាំ បើ ជ្រើសយក វិធាន វិសម្មាត្រ (mesure disproportionnelle) នឹង ហេតុបញ្ហា ជា កំហុស, បើ យល់ឃើញ ស្រាល (sous-estimé) ជា អសមត្ថភាព ប៉ុន្តែបើ ស្ទង់ធាតុត្រូវ (bon dosage) ជា គុណសម្បត្តិ។ គុណសម្បត្តិរបស់ អ្នកដឹកនាំ ជាអាវុធ សំរាប់ ការតស៊ូ នូវ[3] ជា ជម្រង រត្តិកាល[4] សំរាប់ អ្នកតស៊ូ ដូចជា ឡើង និង ពន្លឺ។

## ការតស៊ូជាតិ ជា អាទិ ជា កិច្ចការ នៃទឹកចិត្ត

ព្រោះ ជា ការប្រយុទ្ធគ្នា នៃ មនោសរ:[5] នឹង កម្លាំងអាវុធ គឺ ថា រវាង យុត្តិធម៌ប្រឆាំងនឹង អំណាចផ្តាច់ការ ឬ រវាង ប្រលានច្បាប់ (espace de la lois) ប្រឆាំងនឹង តេរ៉ររកម្ម ឬ អ្នកប្រជាធិតេយ្យ ប្រឆាំងនឹង អ្នកប្រជាហិង្សក៍។ ម្ខាង ជា តំណាង កម្លាំង នៃប្រជាធិបតី (démocratie) ចេញពី ឆន្ទ: ប្រជាជន ធ្វើការតស៊ូ ដើម្បីប្រយោជន៍ទូទៅ, ម្ខាងមួយទៀត ជា កម្លាំង នៃ លទ្ធិផ្តាច់ការ ចេញពី បុគ្គលផ្តាច់ការ ប្រើអំណាច ដើម្បី ស្វែងរក

3 នូវ ប្រើក្នុងន័យ «ហើយនឹង» វចនានុក្រម សម្តេចសង្ឃ ជួន ណាត។
4 រត្តិកាល=នៅពេលរាត្រី (au moment de la nuit)។
5 មនោសរ:= ចិត្តខ្ពស់។

ប្រយោជន៍ឯកជន ក្នុង គោលបំណង រក្សាអំណាច ឬ ដណ្តើម អំណាច។ អំណាច ទាំង ពីរ នេះ មិនអាច រួមរស់ ជា មួយគ្នា បាន ដាច់ខាត ; តាមធម្មជាតិ វាបដិសេធគ្នាទៅវិញទៅ មក ដោយខ្លួនឯង ព្រោះ វា មាន ធាតុ ផ្ទុយគ្នា ស្រឡះ។ គ្រប់ ការប៉ុនប៉ង រក រស់នៅ ជាមួយគ្នា ជា អំពើ ប្រឆាំងនឹង ប្រជាធិបតី និង សុទ្ធនិច្ឆ័យ។ ការពិសោធ មានច្រើនក្រៃលែង មាននៅក្នុង ប្រវត្តិសាស្ត្រ នៃមនុស្សជាតិ បង្ហាញ នូវ បរាជ័យ នៃ សហការ បែប នេះ។ ហើយ រាល់លើក, ប្រជាអំណាច តែងតែ ទទួល រងគ្រោះ ជានិច្ច នៅចំពោះមុខ ល្បិចកល របស់អ្នកផ្តាច់ការព្រោះ សមស្តនិយម[6] តែងតែ មានគោលដៅ បង្កើន ឫទ្ធិ អំណាច ជា អតិបរមា ទាំង ប្រពលតាព និង វិបុលកម្ម[7] ដ្បិត អ្នកផ្តាច់ការ គ្មាន សីលនិច្ឆ័យ (sens moral) សំរាប់ រក ប្រយោជន៍ជាតិ និង ប្រជាពលរដ្ឋ។ ការរួបរួម ឬ ប្រឆាំង ត្រូវ ជ្រើស អោយ ដាច់ស្រាច់ តាំងពី ដើមដំបូង ដាក់ ក្នុងផែនការ កលយុទ្ធ ក្នុង ការតស៊ូជាតិ ព្រោះជ័យជំនេះ អាស្រ័យ ទៅ លើ ជម្រើស ត្រឹមត្រូវ នេះឯង ដ្បិត ជនផ្តាច់ការ តែងតែ យក កលយុទ្ធ នៃ ការរួបរួម នៅក្រោម ការដឹកនាំរបស់ខ្លួន សំរាប់ ធ្វើអោយ កម្លាំង តស៊ូជាតិ ធ្លាក់អន់ថយ ដោយមិនដឹងខ្លួន,ទម្រាំដឹងថាជាល្បិចជា ការហួសពេលទៅហើយ។

## ការតស៊ូជាតិ ក៏ជា កិច្ចការ នៃ ច្បាប់

ព្រោះ ចំណង់ នៃ ទឹកចិត្ត ត្រូវ មាន ច្បាប់ ជា និយតករ, ពុំនោះ វា អាចនឹងនាំឲមាន អនាធិបតេយ្យ ដែល អាចទុកជា សត្រូវនឹង ការតស៊ូជាតិ។ ច្បាប់ សំរាប់គ្រប់គ្រាងការតស៊ូជាតិ មាន ឋានានុក្រម គឺ សិទ្ធិមនុស្ស, ច្បាប់ជាតិ និង ច្បាប់អន្តរជាតិ។ សេរីភាពជា ធាតុ នៃ សិទ្ធិមនុស្ស ដែល មនុស្សលោក ប្រើ សំរាប់ រស់ នៅក្នុង សារលតាព (simplicité)។ សេរីភាព មិនមែន ជា ការប្រយុទ្ធ ប្រឆាំង ដើម្បី ដណ្តើម ពីនរណា នោះ

[6] សមស្តនិយម = Totalitaire។
[7] វិបុលកម្ម= Extension។

ឡើយ ព្រោះ វា មាន នៅក្នុង ធាតុ នៃ មនុស្ស ដែល មនុស្សខ្លួនឯង ត្រូវតែ ការពារ ដោយ ប្រកត់ប្រជា។ ដូច្នេះ ការការពារ សេរីភាព ដែល ទទួល នូវ និគ្រោះ ពីសំណាក់អាជ្ញាធរ មិនមែន ជា ការងើប ឬ បះបោរ ប្រឆាំងនឹង ច្បាប់រដ្ឋ នោះឡើយផ្ទុយ ទៅវិញ គឺ ជា ការ បង្ខំ អោយ អាជ្ញាធរ គោរព ច្បាប់រដ្ឋ អោយបាន ត្រឹមត្រូវ ព្រោះ ច្បាប់ប្រឆាំងនឹង ប្រជាពលរដ្ឋ ពុំមាន នៅក្នុង នីតិរដ្ឋ, តែ វា ជាច្បាប់ នៃ រដ្ឋភេរវកម្មដែល ជា ឧក្រិដ្ឋកម្ម ប្រឆាំងនឹង មនុស្សជាតិ។ នៅចំពោះមុខ អំពើនេះ មាន ច្បាប់ អន្តរជាតិ សំរាប់ការពារ អ្នករងគ្រោះ និង តុលាការ អន្តរជាតិ សំរាប់ វិនិច្ឆ័យទោស ដល់ ជន ដែលបានប្រព្រឹត្ត បទឧក្រិដ្ឋ នេះ។

## ការតស៊ូជាតិ ត្រូវការ សេចក្តីក្លាហាន

តែ មិនមែន សុទ្ធជា សេចក្តីក្លាហាន ងើបឡើងកាន់អាវុធ ប្រឆាំងនឹង អំណាចផ្តាច់ការ នោះឡើយ។ សេចក្តីក្លាហាន មិនមែន ជា ការអំពាវនាវ អោយ មាន កុប្បកម្ម, ការសងសឹក, ការកាប់សម្លាប់ ព្រោះ វាផ្ទុយនឹង គោលការណ៍ នៃ ប្រជាធិបតី។ សេចក្តីក្លាហាន គឺថា មិនទទួលស្គាល់ និង មិនយល់ព្រម ធ្វើសហការ ជាមួយ អំណាចផ្តាច់ការ ; សេចក្តីក្លាហាន គឺ ប្រើ សិទ្ធិ ជា ពលរដ្ឋ មិនស្តាប់បង្គាប់ ក្រិត្យក្រម[8] ដែល រដ្ឋអំណាចផ្តាច់ការ យកវាមក អនុវត្ត សំរាប់ គាបសង្កត់ ប្រជាជន ; សេចក្តីក្លាហាន មិនមែន សំរាប់ ស្វែងរក សក្តតេជ (bravoure) ក្នុងសកម្មភាពហិង្សា តែ ជា ការប្រើប្រាជ្ញា ស្រប ច្បាប់ និង ស្រប សីលធម៌ គឺ ថា ជា សកម្មភាព នៃ សីលគន្ធ (bonne conduite) របស់ អ្នកតស៊ូ ដែល ជា សារជាតិ នៃមនុស្សលោក។ ដូច្នេះ បដិវត្តិន៍ ហិង្សា ដែល បក្សកុម្មុយនិស្ត តែងតែ យកមក អនុវត្ត មិនមែនទុកជា សេចក្តីក្លាហាន នោះឡើយ។ បដិវត្តិន៍ ហិង្សា ជា រូបភាព នៃ អ

[8] មិនស្តាប់បង្គាប់ ក្រិត្យក្រម[8] = désobéissance civique។

នារ្យធម៌ (barbarie) ដែលពួក អ្នកភេរវកម្មនៅក្នុង ពិភពលោក កំពុង យកមក អនុវត្ត ដ៏ព្រៃផ្សៃ បំផុត ក្នុង បច្ចុប្បន្នកាលនេះ។

## ការតស៊ូជាតិ ជា ករណីយកិច្ច នៃ ប្រជាពលរដ្ឋ

នៅពេលដែល ប្រជាជាតិ ត្រូវ ទ័ព បរទេស ឈ្លានពាន ទឹកដី ពលរដ្ឋ ម្នាក់ៗ ត្រូវ មាន ករណីយកិច្ចការពារ បូរណភាពទឹកដី និង អធិបតេយ្យជាតិ។ ករណីយកិច្ច នេះគ្រប់គ្រង ដោយ ច្បាប់ កំណែនទូទៅ ដើម្បី ធ្វើ សង្គ្រាម មហាជន ដែល ជា សង្គ្រាមរំដោះទឹកដី នឹង ការពារ អធិបតេយ្យជាតិ។ សង្គ្រាមមហាជន ពឹកផ្អែក ទៅលើ កម្លាំង កងទ័ពជាតិ ដែលជា កម្លាំងជួរមុខ ក្រោមការដឹកនាំ នៃ រដ្ឋាភិបាល ដើម្បី វាយតបជាបន្ទាន់ ប្រឆាំងនឹង សត្រូវជាតិ គ្រប់ទីកន្លែង និង គ្រប់ពេលវេលា។ សង្គ្រាមមហាជន ត្រូវចាំបាច់មាន ការគាំទ្រ ពីសំណាក់ ប្រជាពលរដ្ឋ ដែលជា កម្លាំងជាតិ ទុក ជា គ្រិះ នៃ ប្រជាជាតិ ដែលមាន កងទ័ពជាតិ ជា កំពែង។ នៅក្នុង មហាជន មាន កម្មករ, កសិករ, អ្នករដ្ឋការ, យុវជន អ្នកចេះដឹង និង សហធម្មិក (clergé) ចូលរួម ការពារជាតិ ប្រកបដោយ ជាតិសម្បជញ្ញៈ (conscience née) នៅក្នុង ការណីកិច្ចជា ពលរដ្ឋមានការទទួលខុសត្រូវ។ នាដការ ទាំងនេះហើយ ត្រូវធ្វើ សកម្មភាព ជានិច្ចជាកាលហើយទៀងទាត់ តាម លទ្ធភាព ជា ពលកម្ម រៀងៗខ្លួន នៅ ក្នុង សង្គ្រាមមហាជន។មហាជន ជាកម្លាំង ជីវពល រាយពេញប្រទេស ជាជំនួយ ដល់ កងទ័ពជាតិ គ្រប់កាលៈទេសៈ នៅ គ្រប់ ទីកន្លែង ដែល មាន វត្តមានខ្មាំងជាតិ, ដូច្នេះ មហាជន ត្រូវទទួល ការហ្វឹកហ្វឺន ខាងផ្នែកយោធា និង ធ្វើ វុធការ នៃ សីលធម៌[9] គ្រប់គ្រាន់ នៅក្នុង អង្គការ ចាត់តាំង ត្រឹមត្រូវ សំរាប់គ្រប់គ្រង ដើម្បី អោយ សកកម្មភាព មាន ប្រសិទ្ធិភាព នៅ ក្នុង យុទ្ធសាស្ត្រ និង កលយុទ្ធ ទូទៅ នៃផែនការ នៃ ការតស៊ូ។

---

[9] ធ្វើ វុធការ នៃ សីលធម៌[9] = réarmement morale។

ជូនកាល ប្រទេស រងការទន្ទ្រាន ត្រូវការជំនួយ ពីប្រទេស ជា មិត្តដើម្បី ការពារខ្លួន ព្រោះ អ្នកឈ្លានពាន មាន មធ្យោបាយ ជា អាវុធយុទ្ធភ័ណ្ឌ ច្រើនសម្បើមៗ សេចក្តីត្រូវការ នេះ ជា ជំនួយ ធម្មានរូប ព្រោះជាការសង្គ្រោះ ប្រទេស រងគ្រោះ ដែល ធ្វើការតស៊ូ រំដោះជាតិៗ ផ្ទុយទៅវិញ ជំនួយ ដែល អ្នកឈ្លានពានទទួល ជា ជំនួយ អសីលធម៌ ព្រោះ ជា មធ្យោបាយ សំរាប់ គង្គានចូល ប្រទេស ដទៃ ដោយ ព្យាបាទ ដើម្បីកាន់កាប់ រកប្រយោជន៍ ទុច្ចរិតៗ

បង្រួញសេចក្តីមក ករណីយកិច្ច ជា នាវ: អាស្រ័យហេតុ (raison d´être) នៃ ប្រជាពលរដ្ឋ ដែល ជារូបភាពពិត របស់ខ្លួនៗ គេ មើលឃើញ អត្តភាព នៃប្រជាពលរដ្ឋ តាម ករណីយកិច្ច របស់ ពលរដ្ឋ នេះឯងៗមួយវិញទៀត ករណីយកិច្ច ជា ការសំដែង មនោសញ្ចេតនា ដោយកាយ ដោយវាចា ចូលរួម ដោះស្រាយ កិច្ចការ សាធារណ: ឬ សង្គ្រោះជាតិ ក្នុងឋាន:ជា ប្រជាពលរដ្ឋធិបតេយ្យ (peuple souverain)ៗ គុណសម្បត្តិ ខ្ពង់មធំបំផុត នៃ ពលរដ្ឋ ឋិត នៅលើ ភាតកម្ម សកម្ម និង ថាមវ័ន្ត ដែលខ្លួន ទទួលបន្ទុក ដោយ អចិត្តក: (assumer volontairement) ជា និរន្ត ដែល មានចែង នៅ ក្នុង សិទ្ធិ របស់ ពលរដ្ឋម្នាក់ៗៗ

## តើ ការតស៊ូជាតិ ជា សត្រូវនឹង សន្តិភាព នោះឬ ?

មនុស្សលោក មាន ធម្មជាតិ បី យ៉ាង, គឺ៖ ស្រឡាញ់ សន្តិភាព, ប្បារម្ភ អំពី អាត្មសុវត្ថិភាព និង ចំណង់រួបរួម រស់នៅ ក្នុង អារ្យសង្គមៗ ធម្មជាតិ ទាំង បីយ៉ាង នេះឯង ជាជីវិត

ប្រតិបត្តិ (vie pratique) របស់ តួអង្គមនុស្ស (être) ដែល ជា តួអង្គ មនុស្ស សង្គម (être social)ៗ មួយវិញទៀត តួអង្គមនុស្ស ត្រូវការ សំដែងមនោសញ្ចេតនាដោយ កាយ ដោយវាចា ជា សេរីជនៗ នៅពេលដែល សេរីភាព ទទួលការគំរាមកំហែងពី អំណាច បែប ណាមួយ ក៏ដោយ, ពេលនោះ សមតា នៃ ធម្មជាតិ ត្រូវ រលាយដោយខ្លួនឯង ដែលនាំ អោយ សង្គមមនុស្ស ធ្លាក់ទៅក្នុង ការរឹកររ ដែល ពួកអ្នកផ្តាច់ការគេ បង្កើតអោយ មានដើម្បី យកមក ធ្វើជា លេស ដណ្តើមអំណាច ឬ ប្រើ អំណាច សំរាប់ ពង្រឹង អំណាច របស់គេ នៅ ក្នុង សណ្តាប់ធ្នាប់សាធារណ: មួយបែប ដែល គេក្លែងឈ្មោះ ថា សន្តិភាព ក្នុងនោះ គេ កំ ទិចចោល ទាំងអស់ នូវ គ្រប់រូបភាព នៃ សេរីភាពៗ សន្តិភាព ក្លែងក្លាយ វា ផ្ទុយពី សន្តិភាព ធម្មជាតិ ព្រោះ សន្តិភាពក្លែងក្លាយ ជា ឧបករណ៍ របស់ អំណាចផ្តាច់ការៗ សន្តិ ភាព នេះ ជា ខ្ញីទ្យាន បុស្បា (ផ្កាគ្រប់យ៉ាង) សំរាប់ បិទបាំង ទុក្ខវេទនារបស់ ប្រជាជន នៅ ក្នុង និវារណាបូរី ចំពោះ អ្នកក្រីក្រ (cité interdite aux pauvres) របស់ អ្នក ដឹកនាំ និង ខ្ញុកញ្ញា នាំគ្នា រស់ ជា ក្តម្ពី ជា ឃាតករ ជា ចោរប្លន់ដីចំការ និទ្ទណ្ឌៗ ផ្ទុយទៅ វិញ សន្តិភាពធម្មជាតិ ជា សន្តិភាព ប្រដាប់អាវុធ ដោយកម្លាំង ប្រជាពលរដ្ឋ សំរាប់ ការពារ សិទ្ធិសេរីភាព របស់ពលរដ្ឋ នៅក្នុងប្រទេស មាននីតិរដ្ឋៗ ពិតប្រាកដណាស់ ថា សន្តិភាព វា ពិតជា ផ្ទុយនឹង អំពើហិង្សា ប៉ុន្តែ សន្តិភាព ក៏មិន ប្បោះចោល ការតស៊ូ តាមគ្រប់ មធ្យោបាយ ប្រឆាំងនឹង សត្រូវជាតិ និងអំណាចផ្តាច់ការៗ សន្តិភាព នៃ ការតស៊ូ ពុំមែន ជា លក្ខខណ្ឌ នៃ ប្រជាធិបតី (démocratie) និង សេរីភាព នោះទេ គឺ វា ជា សារជាតិ នៃ ទ្វេ កត្តានេះ តែម្តង ដែលទុក ជា បដិសរីរ: (anticorps) សំរាប់ បង្កា ឬ ការពារ ទប់ទល់ នឹង កម្លាំងណា ដែលចូលមក កំទិច ខ្លួនៗ ហេតុដូច្នេះ ការតស៊ូ ប្រឆាំងនឹង សត្រូវជាតិគ្រប់

រូបភាព មិនអាចទុក ជា សត្រូវនឹង សន្តិភាព ឬានឡើយ ព្រោះ វា ជា កម្លាំង ស្វ័យគ្រាណ របស់ សន្តិភាព។

## សេចក្ដីសន្និដ្ឋាន

នៅក្នុង មនោសាស្ត្រ នៃ ការបង្កា និង ការពារ ជាតិ នេះហើយ ដែល អ្នកស្នេហាជាតិមាន សេចក្ដីស្រឡាញ់ មាតុភូមិ និង ហ៊ាន បូជា ជីវិត ដើម្បី ជាតិរស់ ក្នុង ការតស៊ូប្រឆាំងនឹង សត្រូវជាតិ។ ការតស៊ូ មិនមែន ជា បដិវត្តន៍ តែជា ចម្លើយ សម្របនឹងបញ្ហាជាតិ ដែល តម្រូវ អោយ ប្រជាពលរដ្ឋ ងើបឡើងតស៊ូ តែប៉ុណ្ណោះ។ ដូច្នេះ ការតស៊ូជា ប្រតិកម្ម តទល់ នឹង សត្រូវជាតិ តាម អាវុធសឹកផង ឬ ជា សកកម្មភាព អចិន្ត្រៃយ៍ នៃ ការបង្កា នូវ សន្តិភាព តាម សន្តិវិធីផង។ អាវុធសឹក និងច្បាប់ ជា ខែល រួមនឹងកម្លាំង អបរាជ័យ របស់ ប្រជាជាតិ ដើម្បី ធ្វើសមិទ្ធិកម្ម នូវ សន្តិភាព ក្នុងនាម យុត្តិធម៌ និង សេចក្ដីស្នេហានៃ មនុស្សជាតិ។ ដូច្នេះ ការតស៊ូ ជា ខ្លឹមសារជាតិ និង ខ្លឹមសារមនុស្សជាតិ ព្រោះ ការតស៊ូ ជា សកកម្មភាព ការពារជាតិ និង សេចក្ដីថ្លៃថ្នូរ នៃ មនុស្សលោក។

សួរថា តើ ប្រជាពលរដ្ឋខ្មែរ កំពុង រស់នៅ មាន ស្មារតីជាតិ បែបណា នៅចំពោះមុខគ្រោះថ្នាក់ជាតិ នាបច្ចុប្បន្នកាល នេះ ? តើ ប្រជាជាតិខ្មែរ ជា ជិណ្ណកាយ (កាយចាស់) លែង មាន សមត្ថចិត្ត (vigueur) សំរាប់ ការពារខ្លួន ? តើ យុវជនខ្មែរ ហ្នោះបង់ចោល នូវ សេចក្ដីសង្ឃឹម នាកាល សេចក្ដីសង្ឃឹម នេះ ជា ក្រពុំបុប្ផា នៃ ជីវិតយុវភាព របស់ខ្លួន ? ស្រណោះ ស្រុកខ្មែរ ! តើ ប្រយោគនេះ ជា ប្រផ្នូល នូវ មរណភាព នៃប្រជាជាតិខ្មែរ ? ខ្មែរ



# មនោសាស្ត្រ នៃ ការតស៊ូជាតិ

សេរីការ

យើង មានសំណួរ ច្រើនម្លេះណាស់  តែ ចម្លើយ នឹង សំណួរ វាមាន តិចបំផុតៗ តែទោះបី តិចឬច្រើន វា ចំបាច់ ត្រូវ មាន ការតស៊ូជាតិ តែមួយ ដើម្បី ជាតិរស់ៗ៚